# Cambodia Clean Up Toolkit

www.cambodiacleanup.com

# មាតិកា

អំពី យុទ្ធនាការ “កម្ពុជាស្អាត” ........................................................................................................២
តើការសំអាតបែបណាខ្លះដែលសាធារណជនអាចចូលរួមរៀបចំបាន?..............................................៣
រៀបចំផែនការសម្អាតរបស់អ្នក ..............................................................................................................៦
របៀបប្រើប្រាស់គេហទំព័រ កម្ពុជាស្អាត .............................................................................................. ៦
ការចូលរួមប្រឡងប្រណាំង បុគ្គលឆ្នើម អង្គភាពឆ្នើមក្នុងយុទ្ធនាការ កម្ពុជាស្អាត ................................១៨

## អំពី យុទ្ធនាការ “កម្ពុជាស្អាត”

យុទ្ធនាការ **“កម្ពុជាស្អាត”** គឺជាយន្តការអចិន្ត្រៃយ៍មួយដែលត្រូវបានផ្តួចផ្តើមដោយរាជរដ្ឋាភិបាលកម្ពុជាក្នុងការជម្រុញការអភិវឌ្ឍបៃតងនៅក្នុងវិស័យទេសចរណ៍។ យុទ្ធនាការនេះ មានគោលបំណងផ្សារភ្ជាប់រវាងប្រជាពលរដ្ឋ សិស្ស-និស្សិត យុវជននៅតាមបណ្តារាជធានី-ខេត្តក្នុងការចូលរួម និងការកែប្រែឥរិយាបថចំពោះការអនុវត្តក្នុងកិច្ចការងារថែរក្សា អនាម័យ ភាពស្អាត និងបរិស្ថាននៅក្នុងទីក្រុង ទីប្រជុំជន និងតាមតំបន់រមណីយដ្ឋានទេសចរណ៍ទូទាំងព្រះរាជាណាចក្រកម្ពុជា។

គេហទំព័រ **“កម្ពុជាស្អាត”** (www.cambodiacleanup) គឺជាទម្រង់ (platform)មួយរបស់យុទ្ធនាការ “កម្ពុជាស្អាត” ដែលត្រូវបានរៀបចំឡើងដើម្បីសម្របសម្រួលទៅដល់សាធារណជនដែលជាអ្នកមានចំណងចូលរួមសកម្មភាពសំអាត ឬអ្នកដែលមានបំណងបង្កើតកម្មវិធីសំអាតនៅក្នុងទីតាំងនានានៅក្នុងព្រះរាជាណាចក្រកម្ពុជា និងបង្កិតការប្រាស្រ័យទាក់ទងរវាងប្រជាពលរដ្ឋ សិស្ស-និស្សិត យុវជន ក្រុមហ៊ុនឯកជន និងប្រតិបត្តិករទេសចរណ៍ជាមួយនឹងអាជ្ញាធរថ្នាក់ក្រោមជាតិតាមរយៈគេហទំព័រនេះ។




ក្រុមហ៊ុន ប្រតិបត្តិករទេសចរណ៍ និងសាធារណជនទាំងអស់អាចធ្វើការស្នើសុំបង្កើតកម្មវិធីសំអាត ឬស្នើសុំចូលរួមក្នុងកម្មវិធីសំអាតនានាដែលមានកំណត់ស្រាប់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងអាចរាយការណ៍ពីទីតាំងដែលមានសំរាមរ៉ាយប៉ាយមកកាន់អាជ្ញាធរមូលដ្ឋានបានតាមរយៈគេហទំព័រ **“កម្ពុជាស្អាត”** (www.cambodiacleanup)។




## តើសាធារណជនអាចចូលរួមការសំអាត ឬស្នើសុំការសំអាតប្រភេទណាខ្លះ?

ប្រសិនបើអ្នកឃើញថា នៅក្នុងទីតាំងណាមួយនៅក្នុងភូមិ សង្កាត់ ឬសហគមន៍ដែលអ្នករស់នៅ ឬ នៅតាមតំបន់រមណីយដ្ឋានទេសចរណ៍នានានៅទូទាំងព្រះរាជាណាចក្រកម្ពុជាមិនស្អាត មានសំរាមពាលវាលពាសកាល ឬមិនមានការទុកដាក់សំរាមឱ្យបានត្រឹមត្រូវនោះទេ អ្នកអាចកំណត់ប្រភេទនៃទីតាំង ថាតើវាស្ថិតនៅក្នុងទីក្រុង ជាឆ្នេរសមុទ្រ ឬជាតំបន់រមណីយដ្ឋានទេសចរណ៍ រួចអ្នកអាចធ្វើការស្នើសុំសំអាតតាមរយៈគេហទំព័រ **"កម្ពុជាស្អាត"** (www.cambodiacleanup) ទៅតាមប្រភេទនៃការសំអាតដូចខាងក្រោម៖

១. ការសំអាតទីក្រុង

២.ការសំអាតឆ្នេរ

៣. ការសំអាតរមណីយដ្ឋានទេសចរណ៍

៤. ការសំអាតតំបន់រោងចក្រ

## តើអ្នកអាចរៀបចំការសំអាតដោយរបៀបណា?

អ្នកអាចរៀបចំកម្មវិធីសំអាតបាន ដោយគ្រាន់តែបង្កើតក្រុមសំអាតដែលមានសមាជិកសមល្មមទៅតាមទំហំទីតាំងដែលអ្នកមានបំណងសំអាត និងគោលបំណងនៃការសំអាត រួចស្នើសុំការសំអាតនោះមកកាន់អាជ្ញាធរមូលដ្ឋាន ដែលជាមន្ត្រីបង្គោលរៀបចំសម្របសម្រួលក្នុងយុទ្ធនាការនេះតាមរយៈគេហទំព័រ www.cambodiacleanup.com។

នៅក្នុងដំណើរការការរៀបចំសំអាត ក្រុមនីមួយៗ តម្រូវឱ្យអនុវត្តតាមការណែនាំតាមដំណាក់កាលដូចខាងក្រោមៈ

***មុនពេលចុះសំអាត***

**ទី១.** អ្នកត្រូវចុះឈ្មោះដើម្បីចូលជាសមាជិកនៃយុទ្ធនាការ "កម្ពុជាស្អាត" នេះជាមុន នៅក្នុងគេហទំព័រ **"កម្ពុជាស្អាត"** (www.cambodiacleanup)

**ទី២.** បន្ទាប់ពីក្លាយជាសមាជិក អ្នកត្រូវបង្កើតក្រុមសំអាតមួយដែលមានសមាជិកសមល្មមក្នុងការរៀបចំកម្មវិធីសំអាត។ សមាជិកនីមួយៗ របស់ក្រុមអ្នកក៏តម្រូវឱ្យចុះឈ្មោះចូលជាសមាជិកជាមុនសិនដែរ ដូចនេះទើបអ្នកអាចបញ្ចូលទិន្នន័យអំពីសមាជិកក្រុមចូលទៅក្នុងប្រព័ន្ធបាន។

**ទី៣.** ដោយចូលទៅក្នុងផ្នែកស្នើសុំការសំអាតនៃគេហទំព័រ (www.cambodiacleanup) អ្នកត្រូវស្នើសុំការសំអាតពីអាជ្ញាធរមូលដ្ឋាននៅក្នុងទីតាំងដែលអ្នកស្នើសុំរៀបចំការសំអាតនោះ

**ទី៤.** បន្ទាប់ពីអ្នកទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានហើយ (ដោយទទួលបាន Notification) អ្នក និងក្រុមអាចចាប់ផ្តើមចុះសំអាតតាមផែនការរបស់ក្រុមបាន

**ទី៥.** អ្នកគួរតែមានរៀបចំរបៀបនៃការសំអាត ដោយរៀបចំផែនការច្បាស់លាស់ពីផែនទីសំអាត ទីតាំងជួបជុំក្រុម ចំណុចចាប់ផ្តើម និងចំណុចបញ្ចប់ រួចបែងចែកសមាជិកក្រុមសំអាតឱ្យច្បាស់តាមតំបន់នីមួយៗ ដើម្បីចៀសវាងការសំអាតស្ទួនគ្នា ហើយចន្លោះទីតាំងមួយចំនួន។

**ទី៦.** ប្រធានក្រុមសំអាតត្រូវពន្យល់ណែនាំសមាជិកក្រុមឱ្យបានច្បាស់លាស់ពីកម្មវត្ថុនៃការរៀបចំការសំអាត ចែកចាយព័ត៌មានចាំបាច់នានាពីកម្មវិធី និងស្ថានភាពទូទៅរបស់ទីតាំងសំអាតដើម្បីចៀសវាងហានិភ័យដែលអាចនឹងកើតមាន(*អ្នកអាចទាញយកគោលការណ៍ណែនាំស្តីពីសុវត្ថិភាព និងបរិស្ថាន នៅក្នុងគេហទំព័រ www.cambodiacleanup.com*) បែងចែកតួនាទីភារកិច្ចរបស់សមាជិកក្រុម (ប្រធាន អនុប្រធាន និងសមាជិក) និងត្រូវដឹងច្បាស់ពីតម្រូវការរបស់ក្រុម ដូចនេះសមាជិកនីមួយៗ អាចសំអាតបានទៅតាមផែនការ។

**ទី៧.** អ្នកត្រូវរៀបចំសម្ភារៈសំរាប់សំអាតឱ្យបានគ្រប់គ្រាន់ ដើម្បីឱ្យបានសមស្របទៅតាមទំហំនៃការសំអាតនីមួយៗ និងអាចប្រើប្រាស់ឡើងវិញបានច្រើនដង

**ទី៨.** ក្នុងការរៀបចំការសំអាតនីមួយៗ អ្នកអាចស្វែងរកការឧបត្ថម្ភនានាពីក្រុមហ៊ុន អាជីវកម្មក្នុងស្រុក ឬអង្គការដែលកំពុងដំណើរការ និងអនុវត្តគោលការណ៍ Corporate Social Responsibility-CSR)

*កំឡុងពេលសំអាត*

**ទី៩.** អ្នកត្រូវផ្តិតយករូបភាព ឬវីដេអូអំពីទីតាំងដែលអ្នកនឹងសំអាត មុននឹងអ្នកចាប់ផ្តើមការសំអាត ដើម្បីរក្សាទុកជាទិន្នន័យសម្រាប់បញ្ចូលនៅក្នុងផ្នែកអាប់ឡូតទិន្នន័យនៃគេហទំព័រ កម្ពុជាស្អាត

**ទី១០.** អ្នកត្រូវសំអាតដោយមានរបៀបរៀបរយ (ចៀសវាងហានិភ័យនានា) និងមានការបែងចែកក្រុមសំអាតឱ្យបានសមរម្យដើម្បីឱ្យការសំអាតមានប្រសិទ្ធភាព

**ទី១១.** អ្នកគួរតែបែងចែកសំរាមដែលអ្នករើស (សំរាមក្រដាស ដបប្លាស្ទិក កំប៉ុងអាលុយមីញ៉ូម កែវ សំណល់ចំណីអាហារ ស្លឹកឈើ -ល-) ដោយកំណត់ថង់ ឬឧបករណ៍វេចខ្ចប់ទៅតាមប្រភេទសំរាម (កែច្នៃបាន សរីរាង្គ និងផ្សេងៗ)។ ការបែងចែកសំរាមបែបនេះ មានសារៈសំខាន់ ព្រោះអ្នកអាចទាញយកផលប្រយោជន៍ពីសំរាមទាំងនោះ និងមានភាពងាយស្រួលទៅដល់ការប្រមូលទិន្នន័យសំរាមសំរាប់គម្រោងនានា)

**ទី១២.** ក្នុងពេលសំអាត អ្នកក៏តម្រូវឱ្យផ្តិតយករូបភាព ឬវីដេអូអំពីសកម្មភាពសំអាត ដើម្បីរក្សាទុកជាទិន្នន័យសម្រាប់បញ្ចូលនៅក្នុងផ្នែកអាប់ឡូតទិន្នន័យនៃគេហទំព័រ កម្ពុជាស្អាត

*ក្រោយពេលសំអាត*

**ទី១៣.** ក្រោយពេលសំអាតចប់ អ្នកត្រូវរៀបចំវេចខ្ចប់ និងទុកដាក់សំរាមទាំងនោះឱ្យបានត្រឹមត្រូវ និងមានសណ្តាប់ធ្នាប់

**ទី១៤.** អ្នកតម្រូវឱ្យផ្តិតយករូបភាពសំរាមដែលអ្នកបានប្រមូល និងផ្តិតយករូបភាព ឬវីដេអូអំពីទីតាំងដែលបានសំអាតរួចរាល់

**ទី១៥.** បន្ទាប់មក ស្នើឱ្យអ្នកផ្សព្វផ្សាយពីសកម្មភាពសំអាតនៅក្នុងបណ្តាញទំនាក់ទំនងសង្គម (Facebook) និងបញ្ចូលទិន្នន័យជាឯកសារ រូបភាព ឬវីដេអូនៅក្នុងផ្នែកអាប់ឡូតទិន្នន័យនៃគេហទំព័រ www.cambodiacleanup.com

## តើអ្នកអាចចូលរួមកម្មវិធីសំអាតដោយរបៀបណា?

ប្រសិនបើអ្នកមិនមានបំណងបង្កើតកម្មវិធីសំអាតដោយខ្លួនឯងទេ ប៉ុន្តែមានបំណងចូលរួមការសំអាត អ្នកអាចស្នើសុំចូលរួមសំអាតជាមួយក្រុមដ៏ទៃ ឬចូលរួមក្នុងកម្មវិធីដែលរដ្ឋបាលថ្នាក់ក្រោមជាតិបានរៀបចំដោយអ្នកអាចចូលទៅក្នុងគេហទំព័រ កម្ពុជាស្អាត (www.cambodiacleanup.com) រួចចុះឈ្មោះចូលរួមជាសមាជិកជាមុនសិន (ករណីដែលអ្នកមិនទាន់បានចុះឈ្មោះពីមុនមក)។ ក្រោយពីអ្នកក្លាយជាសមាជិករួចហើយ អ្នកអាចចូលទៅពិនិត្យមើលកម្មវិធីសំអាត ឬផ្នែកបញ្ជីក្រុម និងចូលក្រុមនៃគេហទំព័រ **កម្ពុជាស្អាត** ដើម្បីស្វែងរកព័ត៌មានអំពីកម្មវិធីសំអាត និងក្រុមសំអាតដែលអ្នកពេញចិត្ត។

បន្ទាប់មកអ្នកអាចស្នើសុំចូលរួមក្រុម ឬកម្មវិធីសំអាតដែលអ្នកពេញចិត្ត នោះប្រព័ន្ធនឹងផ្ញើរសារទៅកាន់ប្រធានក្រុមរបស់កម្មវិធី។ អ្នកនឹងទទួលបានសារបញ្ជាក់ពីការអនុញ្ញាត ប្រសិនបើប្រធានក្រុមបានអនុញ្ញាតការចូលរួមក្នុងកម្មវិធីរបស់ក្រុមដែលអ្នកបានស្នើ ហើយអ្នកក៏អាចទំនាក់ទំនង និងចូលរួមការសំអាតទៅតាមគម្រោងរបស់ក្រុមនោះបាន។

## របៀបប្រើប្រាស់គេហទំព័រ កម្ពុជាស្អាត

គេហទំព័រ **កម្ពុជាស្អាត** (Cambodia Clean Up) ត្រូវបានបង្កើតឡើងដើម្បីសម្រួលទៅដល់សាធារណជនដែលមានបំណងចូលរួម ឬបង្កើតកម្មវិធីសំអាត និងចូលរួមក្នុង**ការប្រឡងប្រណាំង បុគ្គលឆ្នើម អង្គភាពឆ្នើមក្នុងយុទ្ធនាការ កម្ពុជាស្អាត** ដែលជាយន្តការលើកទឹកចិត្តទៅដល់បុគ្គល និងអង្គភាពដែលសកម្មក្នុងកិច្ចការងារថែរក្សា អនាម័យ និងបរិស្ថាន។

ខាងក្រោមនេះ ជាការណែនាំពីរបៀបប្រើប្រាស់គេហទំព័រ **កម្ពុជាស្អាត៖**

១. ដំណើរការនៃការចុះឈ្មោះជាសមាជិក



➢ សូមស្វែងរកប៊ូតុង ***ចុះឈ្មោះ*** (ដូចរូបទី១)




*(រូបទី១)*

➢ សូមបំពេញព័ត៌មានក្នុងទម្រង់ចុះឈ្មោះ (ដូចរូបទី២)



គណនីដែលបានបង្កើតរួច នឹងត្រូវប្រើជារៀងរហូត។ ប្រសិនបើអ្នកធ្លាប់បានបង្កើតគណនីរួចហើយ អ្នកមិនត្រូវបង្កើតគណនីថ្មីទៀតឡើយ។ សូមចូលប្រព័ន្ធដោយប្រើប្រាស់ព័ត៌មានគណនីដែលមានស្រាប់។ ចូលប្រព័ន្ធ

**ចុះឈ្មោះ**

**រូបថត**

Browse... No file selected.

**នាម (ខ្មែរ)**

នាម (ខ្មែរ)

**គោត្តនាម (ខ្មែរ)**

គោត្តនាម (ខ្មែរ)

**នាម (ឡាតាំង)**

នាម (ឡាតាំង)

**គោត្តនាម (ឡាតាំង)**

គោត្តនាម (ឡាតាំង)




*(រូបទី២)*

- ក្រោយពេលអ្នកបំពេញព័ត៌មានបានត្រឹមត្រូវហើយ សូមអ្នកចុចប៊ូតុង ***បង្កើត*** នោះអ្នកនឹងទទួលបានសារជាប់ប៊ូតុង ***បង្កើត*** ដូចបង្ហាញក្នុងរូបខាងក្រោម (រូបទី៣)




*(រូបទី៣)*

- បន្ទាប់មកទៀត អ្នកនឹងឃើញសារណែនាំអំពីការពិនិត្យអ៊ីម៉ែល (ដូចរូបទី៤)




*(រូបទី៤)*

➢ ដើម្បីឱ្យគណនីរបស់អ្នកដំណើរការបាន អ្នកត្រូវឱ្យចូលទៅអ៊ីម៉ែលដែលអ្នកប្រើប្រាស់ ដើម្បីផ្ទៀងផ្ទាត់ និងដាក់ឱ្យដំណើរការគណនី សូមចុចលើ តំណភ្ជាប់ទៅតាមការណែនាំ (ដូចរូបទី៥)




*(រូបទី៥)*

➢ បន្ទាប់ពីបានចុចលើតំណភ្ជាប់ហើយ ភ្លាមនោះអ្នកនឹងឃើញទំព័រមួយទៀតបង្ហាញថា គណនីរបស់អ្នកត្រូវបានដាក់ឱ្យដំណើរការដោយជោគជ័យ (ដូចរូបទី៦)




*(រូបទី៦)*

២. ការចូលគណនី

➢ ក្រោយពីអ្នកបង្កើតគណនីបានជោគជ័យ អ្នកតម្រូវឱ្យវាយអ៊ីម៉ែល និងពាក្យសំងាត់ (ដូចរូបទី៧) ដើម្បីអាចចូលគណនីដើម្បីប្រើប្រាស់បាន។




*(រូបទី៧)*

➢ ក្រោយពេលចូលប្រព័ន្ធគណនី អ្នកនឹងឃើញមានប៊ូតុង គណនី (ដូចរូបទី៨) បន្ថែម




*(រូបទី៨)*

➢ នៅក្នុងផ្នែកនេះមានមុខងារមួយចំនួនដែលអ្នកអាចប្រើប្រាស់បានដូចជា៖

1. ការបង្កើតក្រុម
2. បញ្ជីក្រុម និង ការចូលក្រុម
3. រាយការណ៍សម្រាម
4. ការស្នើសុំសំអាត
5. អាប់ឡូតទិន្នន័យ
6. ព័ត៌មានគណនី

## ១. ការបង្កើតក្រុម

ចូលបំពេញឈ្មោះក្រុម និង ជ្រើសរើសសមាជិកក្រុមរបស់អ្នកអោយបានត្រឹមត្រូវ។



- នៅចំណុចនេះយើងអាចបន្ថែមសមាជិកបានទៀតផងដែរ
- សូមបញ្ជាក់សមាជិកក្រុមត្រូវការធ្វើការយល់ព្រមទើបមានសទ្ធិជាសមាជិកក្រុមបាន




## ២. បញ្ជីក្រុម និងស្នើសុំចូលរួមក្រុម

- ចំនួនក្រុមរបស់យើងដែលបានបង្កើត
- យើងអាចចុចមើលចំនួនសមាជិកក្រុមនៃក្រុមនីមួយៗបាន នឹង បន្ថែមសមាជិកបានផងដែរ




## ៣. របាយការណ៍សំរាម






- ចូលធ្វើការដៅទីតាំងដែលអ្នករាយការណ៍អោយបានត្រឹមត្រូវ
- ក្រោយពីបានបំពេញទិន្នន័យរួច សូមចុចប៊ូតុង រក្សាទុក




## ៤. ការស្នើសុំសំអាត

- ប៊ូតុង (ការស្នើសុំសំអាត) ជាប៊ូតុងសំរាប់ស្នើសុំសំអាតដែលក្រុមអ្នកចង់ធ្វើការសំអាត
- ប៊ូតុង (កាលវិភាគសំអាត) ជាប៊ូតុងសំរាប់ស្នើសុំសំអាតដែលតាមកាលវិភាគក្រសួងដាក់



* ការស្នើសុំសំអាតដោយក្រុមផ្ទាល់ទៅតាមទីតាំងដែលក្រុមគ្រោងនឹងសំអាត

- ប៊ូតុង (ការស្នើសុំសំអាត) ជាប៊ូតុងសំរាប់ស្នើសុំសំអាតដែលក្រុមអ្នកចង់ធ្វើការសំអាត



* ការស្នើសុំសំអាតតាមកម្មវិធីដែលមានស្រាប់រៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិ




## ៥. អាប់ឡូតទិន្នន័យ

ការអាប់ឡូតទិន្នន័យ គឺមានគោលបំណងឱ្យក្រុមការងារសំអាតអាចរាយការណ៍នូវសកម្មភាពសំអាត និងទិន្នន័យសំរាមដែលក្រុមប្រមូលបានក្នុងសកម្មភាពសំអាតនីមួយៗ



## II. ទិន្នន័យនៃទីតាំងសម្អាត

**ប្រភេទ ៖** ○ ទីក្រុង ○ តំបន់ឆ្នេរ ○ រមណីយដ្ឋានទេសចរណ៍

**ទីតាំង ៖** ○ ដងវិថី ○ សួនច្បារ/ទីសាធារណៈ ○ ឆ្នេរសមុទ្រ ○ ផ្សារ ○ សាលារៀន ○ ផ្សេងៗ

**ខេត្ត/ក្រុងនៃទីតាំង** : សូមធ្វើការជ្រើសរើស

**ស្រុក/ខណ្ឌនៃទីតាំង** : សូមធ្វើការជ្រើសរើស

**កាលបរិច្ឆេទនៃការសម្អាត** : ជ្រើសរើសកាលបរិច្ឆេទសម្អាត

**ប្រវែងទីតាំងសម្អាត** : គីឡូម៉ែត

**ឈ្មោះដងវិថី/សួន/ទីធ្លាសាធារណ** : បំពេញឈ្មោះឲ្យបានត្រឹមត្រូវ

## III. ប្រភេទសំរាមរើសបាន

**១. តើមានសំរាមដែលអាចកែច្នៃបានឬទេ?**

☐ មាន ☐ មិនមាន

**ប្រសិនបើមាន សូមបញ្ជាក់៖**

☐ ដបប្លាស្ទិក ☐ ដបកែវ ☐ កំប៉ុងអាលុយមីញ៉ូម ☐ ក្រដាស/ក្រដាសកាតុង

☐ ផ្សេងៗ

**២. តើមានសំរាមណាខ្លះដែលមិនសូវបានប្រទះឃើញនៅរាយប៉ាយ?**

**សូមបញ្ជាក់ឈ្មោះ:** បំពេញឈ្មោះឲ្យបានត្រឹមត្រូវ

**៣. តើប្រភេទសំរាមអ្វីខ្លះដែលអ្នកប្រទះឃើញច្រើននៅកំឡុងពេលសំអាត?**

☐ ប្រអប់ស្នោ ☐ បំពង់ទុយោ ☐ កំប៉ុងភេសជ្ជៈ ☐ ថង់ប្លាស្ទិក

☐ ចានស្នោ ☐ គំរបដប/កំប៉ុង ☐ ដបប្លាស្ទិក ☐ ក្រដាស

☐ ក្រដាសកាតុង ☐ កន្ទុយបារី ☐ កង់ឡានចាស់ៗ ☐ ខោទឹកនោម

☐ ថ្មពិល ☐ ដែក ☐ កំទេចឈើ/ស្លឹកឈើ ☐ សំរាមផ្ទះបាយ

☐ គ្រឿងសង្ហារឹម ☐ គ្រឿងសំណង់ ☐ ម្ជុល/សឺរ៉ាំង ☐ អាចម៍សត្វ

☐ កំប៉ុង/ធុងសាំង ឬប្រេង ☐ គ្រឿងអេឡិចត្រូនិច (ទូរទស្សន៍ កុំព្យូទ័រ...)


VI.ឯកសារជារូបភាព
រូបភាពមុនពេលសំអាត
កន្លែងបង្ហាញរូបភាព
Browse ...
សកម្មភាពពេលសំអាត
កន្លែងបង្ហាញរូបភាព
Browse ...
រូបភាពបក្រោយពេលសំអាត
កន្លែងបង្ហាញរូបភាព
Browse ...
រូបភាពតារាងទិន្នន័យ
កន្លែងបង្ហាញរូបភាព
Browse ...
រក្សាទុក
បញ្ជាក់៖ បើអ្នកប្រទះសំភារណាដែលអ្នកមិនស្គាល់ច្បាស់ សូមកុំរើស ឬប្រមូលពួកវា។

# ៦. ព័ត៌មានគណនី



បញ្ជីគ្រប់គ្រង
បង្កើតក្រុម
បញ្ជីក្រុម និង ចូលក្រុម
រាយការណ៍សម្រាម
ការស្នើរសុំសំអាត
អាប់ឡូតទិន្នន័យ
ព័ត៌មានគណនី
ចាកចេញ
ព័ត៌មានផ្ទាល់ខ្លួន
អ៊ីម៉ែល
ពាក្យសម្ងាត់
រូបថតសហគ្រិន
គោត្តនាម (ខ្មែរ) *
យ៉ុន
នាម (ខ្មែរ) *
ដារា
គោត្តនាម (ឡាតាំង) *
Yon
នាម (ឡាតាំង) *
Dara
ភេទ *
ប្រុស
ទូរស័ព្ទ
098898989
អាសយដ្ឋាន
PP
រក្សាទុក

## តើអ្វីជាការប្រឡងប្រណាំង បុគ្គលឆ្នើម អង្គភាពឆ្នើមក្នុងយុទ្ធនាការ កម្ពុជាស្អាត? តើអ្នកអាចចូលរួមដោយរបៀបណា?

ដើម្បីជំរុញការចូលរួមឱ្យបានទូលំទូលាយ និងជាការលើកទឹកចិត្តទៅដល់សាធារណជនទូទៅដែលបានចូលរួមក្នុងយុទ្ធនាការ **កម្ពុជាស្អាត** គណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាតស្មើរៀបចំឱ្យមាន**ការប្រឡងប្រណាំង បុគ្គលឆ្នើម អង្គភាពឆ្នើមក្នុងយុទ្ធនាការ កម្ពុជាស្អាត ប្រចាំឆ្នាំ** ដែលយន្តការលើកទឹកចិត្ត និងទ្រទ្រង់ទៅដល់យុទ្ធនាការ **កម្ពុជាស្អាត**។

សាធារណៈជនដែលមានបំណងចូលរួមក្នុងការប្រឡងប្រណាំង បុគ្គលឆ្នើម អង្គភាពឆ្នើមក្នុងយុទ្ធនាការ **កម្ពុជាស្អាត** គ្រាន់តែះ

១. បង្កើតក្រុម និងរៀបចំកម្មវិធីសំអាត

២. អាប់ឡូតទិន្នន័យនៃសកម្មភាពសំអាតនីមួយៗ របស់ខ្លួន

ក្នុងន័យនេះ អ្នកត្រូវអនុវត្តតាមជំហាននៃការរៀបចំសំអាតដែលមានលំអិតនៅក្នុងការណែនាំសំអាត រួចបញ្ចូលនិន្នន័យសំអាតនីមួយៗ នៅក្នុងផ្នែកអាប់ឡូតនិន្នន័យនៃគេហទំព័រ **កម្ពុជាស្អាត** (www.cambodiacleanup.com)។ ប្រសិនបើអ្នក បានបង្កើតក្រុមសំអាត និងរៀបចំកម្មវិធីសំអាតពីមុនរួមមកហើយ អ្នកគ្រាន់តែបញ្ចូលនិន្នន័យសំអាតនីមួយៗដែលអ្នកបានរៀបចំនោះ នៅក្នុងផ្នែកអាប់ឡូតនិន្នន័យនៃគេហទំព័រ កម្ពុជាស្អាតជាការស្រេច។ ជ័យលាភីនឹងទទួលបាន ពានរង្វាន់ Clean City Hero និងវិញ្ញាបនបត្របញ្ជាក់ពីការចូលរួមក្នុងកិច្ចការងារបរិស្ថាន សង្គម និងសេដ្ឋកិច្ច។

